ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

NATIONAL PARALYMPIC COMMITTEE OF CAMBODIA

លេខៈ...០២៣.....គជបក/២០១៣

**អគ្គលេខាធិការ គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**និងជា ប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

**កម្មវត្ថុៈ** សូមគោរពស្នើសុំគោលការណ៍ ដើម្បីធ្វើជាម្ចាស់ផ្ទះរៀបចំ កីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ ២០២៣ នៅប្រទេសកម្ពុជា។

**យោងៈ**
- ចំណាប់អារម្មណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ អនុញ្ញាតជូនគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ ២០២៣។
- លិខិតចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៣ របស់ប្រធានសហព័ន្ធកីឡាអាស៊ានប៉ារ៉ាហ្គេម។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ មេត្តាជ្រាបថាៈ កីឡាអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Game) ត្រូវបានរៀបចំឡើងដូចកីឡាស៊ីហ្គេម (SEA Game) ហើយត្រូវបានយល់ព្រម និងទទួលស្គាល់ពីបណ្តាប្រទេសអាស៊ាន។ សហព័ន្ធកីឡាអាស៊ានប៉ារ៉ាហ្គេមត្រូវបានបង្កើតឡើង និងដឹកនាំការប្រកួតលើកទី១ នៅប្រទេសម៉ាឡេស៊ី ឆ្នាំ ២០០១, និងបន្តដឹកនាំការប្រកួតលើកទី២ នៅប្រទេសវៀតណាម ឆ្នាំ ២០០៣, លើកទី៣នៅប្រទេសហ្វីលីពីន ឆ្នាំ ២០០៥, លើកទី៤នៅប្រទេសថៃ ឆ្នាំ ២០០៧, លើកទី៥នៅប្រទេសម៉ាឡេស៊ី ឆ្នាំ ២០០៩, លើកទី៦នៅប្រទេសឥណ្ឌូនេស៊ី ឆ្នាំ ២០១១ និងលើកទី៧នៅប្រទេស ភូមា នៅថ្ងៃទី ១៤ ដល់ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤។ ប្រទេសដែលរៀបចំកីឡាស៊ីហ្គេម (SEA Game) ត្រូវបន្តរៀបចំកីឡាអាស៊ានប៉ារ៉ាហ្គេម ដោយយកហេដ្ឋារចនាសម្ព័ន្ធ, ការគ្រប់គ្រង, រដ្ឋបាល, ទីលានប្រកួត, ផ្ទះកីឡាករស្នាក់នៅ, និងឧបករណ៍ប្រើប្រាស់ផ្សេងៗ ទៀតបន្តពីការរៀបចំស៊ីហ្គេម។

ថ្មីៗនេះ ប្រធានសហព័ន្ធកីឡាអាស៊ានប៉ារ៉ាហ្គេម បានធ្វើសំណើសុំ គោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ អនុញ្ញាតប្រទេសកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅឆ្នាំ ២០២៣ បន្ទាប់ពីការរៀបចំកីឡាស៊ីហ្គេម។

ដោយប្រទេសកម្ពុជា ជាសមាជិកពេញសិទ្ធិរបស់សហព័ន្ធអាស៊ានប៉ារ៉ាហ្គេម រួមមាន ១១ប្រទេស នៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ បូកប្រទេសទីម័រឡេស្តេ ហើយក្នុងក្រុមប្រឹក្សាសហព័ន្ធអាស៊ានប៉ារ៉ាហ្គេម **សម្តេចអគ្គមហាសេនាបតីតេជោ** ជាសមាជិកពេញសិទ្ធិដោយ សម្តេចអគ្គមហាសេនាបតីតេជោ ជាប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។ ការទទួលរៀបចំធ្វើជាម្ចាស់ផ្ទះជា គុណប្រយោជន៍, ឥទ្ធិពល និងឧត្តមភាពកម្ពុជា លើវិស័យពិការភាព នៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ពិសេសសម្រាប់ជនពិការទាំងក្នុងប្រទេស និងជនពិការមកពីប្រទេសទាំង ១១ ក្នុងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេចអគ្គមហាសេនាបតីតេជោ មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះបំផុត ។

សូម សម្តេចអគ្គមហាសេនាបតីតេជោ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងភក្តីភាពអំពីខ្ញុំបាទ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣

**ដោយគោរពបំផុត**

NATIONAL PARALYMPIC COMMITTEE OF CAMBODIA

**យី ចាសនា**

**គោរពភ្ជាប់ជូន**

- លិខិតរបស់ប្រធានសហព័ន្ធកីឡាអាស៊ានប៉ារ៉ាហ្គេម ១ច្បាប់ ជាភាសាអង់គ្លេស

16.5.13